**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

# ការចាប់ផ្តើមទទួលពាក្យសុំចូលរួម
# ការប្រឡងចម្រៀងណូដូជីម៉ាន់លើកទី៨

លេខ: 04 PR-17/EoJ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយនឹងជម្រាបជូនថា ស្ថានទូតរួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន(CJCC) នឹងរៀបចំនូវ**ការប្រឡងចម្រៀងណូដូជីម៉ាន់លើកទី៨** (ការប្រឡងចម្រៀងភាសាជប៉ុន) នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ នៅ CJCC ។ កម្មវិធីលម្អិតមានដូចខាងក្រោម៖

- កម្មវិធីប្រឡងជម្រុះនៅទីក្រុងភ្នំពេញ៖ ថ្ងៃសៅរ៍ ទី១៧ ខែមិថុនា ឆ្នាំ២០១៧ ពេលព្រឹក និង រសៀល នៅ CJCC រាជធានីភ្នំពេញ
- កម្មវិធីប្រឡងជម្រុះនៅខេត្តសៀមរាប៖ ថ្ងៃសៅរ៍ ទី៨ ខែកក្កដា ឆ្នាំ២០១៧ ពេលរសៀល នៅមជ្ឈមណ្ឌលព័ត៌មានបាយ័ន ខេត្តសៀមរាប
- ការប្រឡងផ្តាច់ព្រ័ត្រ៖ ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០១៧ ពេលរសៀល នៅ CJCC

យើងខ្ញុំសូមស្វាគមន៍អ្នកសិក្សាភាសាជប៉ុនគ្រប់កម្រិតដើម្បីចូលរួមប្រឡងចម្រៀងនេះ។ ពាក្យសុំចូលរួមប្រឡងអាចរកបាន តាមរយៈអាស័យដ្ឋាន៖ http://www.kh.emb-japan.go.jp/culture/2017/Nodojiman/20170418-a.pdf ។ ពាក្យសុំ នឹងចាប់ផ្តើមទទួលរហូត

ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ នៅស្ថានទូតជប៉ុន ឬ ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋាន៖ info.jpn@pp.mofa.go.jp។

ការប្រឡងចម្រៀងណូដូជីម៉ាន់(ចម្រៀងភាសាជប៉ុន) ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ក្នុងគោលបំណងលើកទឹកចិត្តអ្នកសិក្សាភាសាជប៉ុនបានអនុវត្តការបញ្ចេញសម្លេងជាភាសាជប៉ុន។ លើសពីនេះទៀតការប្រឡងនេះក៏មានគោលបំណងពង្រឹងចំណងមិត្តភាព និងការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រជាជនជប៉ុន និងកម្ពុជាតាមរយៈចម្រៀងភាសាជប៉ុនផងដែរ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៨ ៨៧០ (១១២២) ឬ ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋាន៖ info.jpn@pp.mofa.go.jp ។

---